ឯកសារស្រាវជ្រាវសង្ខេប

ព្រឹទ្ធសភា ភូមិភាគទី៦

# បញ្ហាប្រឈមនៃការផ្តល់សេវារដ្ឋបាលនៅថ្នាក់ឃុំ សង្កាត់ ក្នុងស្រុកបាត្តី ខេត្តព្រៃវែង


អ្នកទទួលខុសត្រូវៈ កញ្ញា តាន់ សុគន្ធកល្យាណ(មន្ត្រីហាត់ការមកពីព្រឹទ្ធសភា)

អ្នកចូលរួមៈ លោក ខាំ វ៉ាន់ដា(អ្នកស្រាវជ្រាវ វ.ស.ក)

ឃីន សូហ្សេសាវ (មន្ត្រីស្រាវជ្រាវមកពីប្រទេសមីយ៉ាន់ម៉ា)

អ្នកសម្របសម្រួលៈ លោក នូ កែវសុទ្ធា(មន្ត្រីស្រាវជ្រាវជាន់ខ្ពស់ វ.ស.ក)



ខែមិនា ឆ្នាំ២០១៦

**វិទ្យាស្ថានសភាកម្ពុជា**

**កំណត់សម្គាល់**

វិទ្យាស្ថានសភាកម្ពុជា (វ.ស.ក)គឺជាស្ថាប័នឯករាជ្យមួយដែល ផ្តល់ការគាំទ្រដល់សភាកម្ពុជា តាមរយៈការផ្តល់នូវឯកសារស្រាវជ្រាវទៅតាមសំណើរបស់សមាជិក-សមាជិកា និងគណៈកម្មការជំនាញរបស់រដ្ឋសភា-ព្រឹទ្ធសភា ដែលមានការវិភាគទៅលើបញ្ហាដែលកំពុងតែកើតមាននៅពេលបច្ចុប្បន្ន និងដែលអាចនឹងកើតឡើងនាពេលអនាគត លើប្រធានបទការរៀបចំច្បាប់ និងគោលនយោបាយសាធារណៈ។ ឯកសារទាំងនេះផ្តល់នូវព័ត៌មានផ្សេងៗដែលពាក់ព័ន្ធនឹងការងារសភា និងការងារមណ្ឌល ឬភូមិភាគរបស់សមាជិក-សមាជិការសភា ក៏ប៉ុន្តែ រាល់អត្ថន័យដែលមាននៅក្នុងឯក-សារទាំងនេះមិនមែនតំណាង ឬឆ្លុះបញ្ចាំងអំពី ទស្សនៈផ្ទាល់របស់វិទ្យាស្ថានសភាកម្ពុជា សភា ឬសមាជិក-សមាជិកាណាម្នាក់នោះឡើយ។

ខ្លឹមសារនៃឯកសារទាំងនេះមានកំណត់នូវកាលបរិច្ឆេទរៀបចំច្បាស់លាស់ និងអាចប្រើប្រាស់សម្រាប់តែជាឯក-សារយោងប៉ុណ្ណោះ។ ឯកសារទាំងនេះមិនមានគោលបំណងផ្តល់ប្រឹក្សាផ្នែកច្បាប់ ឬទៅលើគោលនយោបាយណាមួយឡើយ ហើយក៏មិនបានធ្វើការសិក្សាអោយបានគ្រប់ប្រធានបទ ឬរាល់ខ្លឹមសារលម្អិតដែលពាក់ព័ន្ធនឹងបញ្ហាដែលបានលើកឡើងនោះដែរ។

ខ្លឹមសារនៃឯកសារស្រាវជ្រាវនេះស្ថិតក្រោមច្បាប់ជាធរមានរបស់កម្ពុជា និងកិច្ចព្រមព្រៀងអន្តរជាតិស្តីពីសិទ្ធិអ្នកនិពន្ធ។ រាល់ការរៀបចំឡើងវិញដោយដកស្រង់នូវផ្នែកណាមួយ ឬខ្លឹមសារទាំងស្រុងនៃឯកសារស្រាវជ្រាវនេះ ត្រូវមានការអនុញ្ញាតពីវិទ្យាស្ថាន។

រក្សាសិទ្ធិ ឆ្នាំ២០១៦ វិទ្យាស្ថានសភាកម្ពុជា (វ.ស.ក) ។

# មាតិកា

១.សេចក្តីផ្តើម ........ 4

២.ការផ្តល់សេវារដ្ឋបាល និងកម្រៃសេវានៅថ្នាក់ឃុំ នៅក្នុងខេត្តព្រៃវែង ........ 4

៣សង្កាត់មានសុវត្ថិភាព/ឃុំ ........ 6

៤. ទំនាក់ទំនងរវាងថ្នាក់ឃុំ និងថ្នាក់ស្រុក ព្រមទាំង ថ្នាក់ឃុំ និងប្រជាជន ពាក់ព័ន្ធនឹងតម្លៃសេវា រដ្ឋបាល និងភូមិ ឃុំសង្កាត់មានសុវត្ថិភាព/ ........ 8

៥សន្និដ្ឋាន ........ 10

គន្ធនិទ្ទេស ........ 11

## ១.សេចក្តីផ្តើម

ចាប់តាំងពីឆ្នាំ២០០២ បន្ទាប់ពីការបោះឆ្នោតក្រុមប្រឹក្សាឃុំសង្កាត់លើកទី១ កំណែទម្រង់ វិមជ្ឈការ និងវិសហមជ្ឈការនៅប្រទេសកម្ពុជាមានវឌ្ឍនភាពគួរឲ្យកត់សម្គាល់។ កំណែទម្រង់ទាំងពីរនេះមិនត្រឹមតែសម្រេចបាននូវសមិទ្ធិផលដ៏សំខាន់ដែលរួមទាំង សន្តិភាព និងស្ថេរភាពនៅថ្នាក់មូលដ្ឋានប៉ុណ្ណោះទេ វាថែមទាំង បង្កលក្ខណៈងាយស្រួលដល់ក្រុមប្រឹក្សាថ្នាក់មូលដ្ឋានដែលត្រូវបានជ្រើសតាំង ក្នុងការផ្តល់សេវាហេដ្ឋារចនាសម្ព័ន្ធវ័ន្តជនបទ[1] ការអន្តរាគមន៍កិច្ចការសង្គម និងសេវារដ្ឋបាលដ៏ទៃទៀត។[2] ក្នុងឯកសារជំនួយស្មារតីនេះ តួនាទី និងបញ្ហាប្រឈមរបស់ក្រុមប្រឹក្សាឃុំសង្កាត់ ដែលក្នុងនោះពួកគេជាតំណាងឲ្យប្រជាពលរដ្ឋថ្នាក់មូលដ្ឋាន និងជាអ្នកផ្តល់សេវាសាធារណៈ ជាចំណាប់អារម្មណ៍។[3]

ឯកសារជំនួយស្មារតីនេះនឹងធ្វើការស្វែងយល់ និងផ្តោតលើបញ្ហាប្រឈមក្នុងផ្តល់សេវារដ្ឋបាលនៅកម្រិតឃុំសង្កាត់ ដោយសង្កត់ធ្ងន់លើ កម្រៃនៃការផ្តល់សេវារដ្ឋបាល ទំនាក់ទំនងរវាង ក្រុមប្រឹក្សាឃុំ និងថ្នាក់ស្រុក ព្រមទាំង រវាងក្រុមប្រឹក្សាឃុំ និងប្រជាពលរដ្ឋ និងបញ្ហាភូមិ ឃុំមាន សុវត្ថិភាព និងនឹងពិភាក្សាលើថាតើគួរតែកែលម្អបញ្ហាប្រឈមទាំងនេះយ៉ាងណា។ ការសិក្សានេះផ្អែកលើទិន្នន័យដែលមានស្រាប និងការពិគ្រោះយោបល់ជាមួយសមាជិក-សមាជិកាព្រឹទ្ធសភាភូមិភាគទី៦ នៃព្រឹទ្ធសភា ។

## ២.ការផ្តល់សេវារដ្ឋបាល និងកម្រៃសេវានៅថ្នាក់ឃុំ នៅក្នុងខេត្តព្រៃវែង

សេវាសាធារណៈគឺភ្ជាប់ជាមួយ នឹងការផ្តល់សេវាលើវិស័យដ៏ច្រើនក្រៅពីវិស័យសុខភាព វស័យការអប់រំ សេវាទឹកស្អាត និងបញ្ហាអនាម័យ និង សេវារដ្ឋបាលផ្សេងៗទៀតដែលត្រូវបានផ្តល់ដោយរដ្ឋាភិបាល។[4] នៅក្នុងបរិបទឃុំ/សង្កាត់
នៅក្នុងប្រទេសកម្ពុជា ការផ្តល់សេវារដ្ឋបាលរួមមានសេវាសំខាន់ៗពីរៈ (១) ការចុះបញ្ជីរដ្ឋប្បវេណីដូចជាសំបុត្រកំណើត អត្តសញ្ញាណប័ណ្ណ សៀវភៅស្នាក់នៅ សៀវភៅគ្រួសារ។ល។ និង(២) ការចេញលិខិតអនុញ្ញាតដល់ប្រជាពលរដ្ឋដូចជា លិខិតបញ្ជាក់ភាពនៅលីវ មេម៉ាយ ឬពោះម៉ាយ ។ល។[5] សេវារដ្ឋបាលទាំងនេះ និង

---

[1] EIC, *Report of the Second Citizen Satisfaction Survey in Target Commune of the Laar Project* (Phnom Penh, 2010). Available online: http://www.pactcambodia.org/Publications/LAAR/2nd_Citizen_Satisfaction_Survey_Report_June2010.pdf [Accessed.

[2] COMFREL, *Assessment of the Second Term of Decentralization in Cambodia: Commune Council Performance and Citizens' participation 2007-2012* (Phnom Penh 2013). Available online: http://www.comfrel.org/eng/components/com_mypublications/files/390033Final_report_of_the_Second_Term_of_DD_English.pdf [Accessed 23, February, 2016].

[3] R. Kram, *The Law on the Administration and Management of Commune/Sangkat.* (Phnom Penh.

[4] M. Robinson, 'Introduction: Decentralising Service Delivery ? Evidence and Policy Implications'. IDS Bulletin 38 conducted by no.1 (2007). Available online: ftp://ftp.solutionexchange-un.net.in/public/decn/cr/res09070813.pdf.

[5] RGC, *Inter-MInistrial Prakas on the Provision of Administrative Services to Sub-National Administration* (Phnom Penh.

កម្រៃសេវាទាំងនោះ ត្រូវបានធ្វើប្រតិភូកម្មពីរដ្ឋាភិបាលកណ្តាល ទៅរដ្ឋបាលថ្នាក់ក្រោមជាតិ រួមបញ្ចូលទាំងរដ្ឋបាល ឃុំ/សង្កាត់ ដោយយោងទៅតាមសេចក្តីប្រកាសអន្តរក្រសួងស្តីពីការផ្តល់[នូវសិទ្ធិក្នុងការផ្តល់]សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិដែលបានចុះនៅថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៣។[6] ការធ្វើប្រតិភូកម្មនេះដែរ បានធ្វើឲ្យរដ្ឋបាលឃុំ/សង្កាត់មានស្វយត័ភាពក្នុងការរក ប្រកពចំណូលបន្ថែមលើកម្រៃសេវារដ្ឋបាល (ប្រជាពលរដ្ឋ និងអ្នកប្រើប្រាស់សេវា បង់កម្រៃសេវាទៅរដ្ឋបាលមូលដ្ឋាន)។ ដូច្នេះ រដ្ឋបាលឃុំ-សង្កាត់ប្រហែលជាមានថវិកាច្រើនជាងមុនសម្រាប់អភិវឌ្ឍតំបន់របស់ពួកគាត់។

តម្លៃសេវារដ្ឋបាលនេះដែលបានផ្តល់ដោយ ឃុំ/សង្កាត់ នៅគ្រប់ខេត្ត ក្រុងទូទាំងប្រទេសកម្ពុជា គឺចាប់ពី១០០០រៀលទៅដល់៣០.០០០រៀល[7] ចាប់ពី៣ថ្ងៃ
(ឧទាហរណ៍ះច្បាប់ចម្លងនៃសំបុត្រកំណើត និងសំបុត្រអាពាហ៍ពិពាហ៍)ទៅ៧ថ្ងៃ (ឧទាហរណ៍៖ លិខិតបញ្ជាក់ប្រវត្តិដីធ្លី)សម្រាប់សេវាជាក់លាក់ណាមួយ។ ថ្វីបើពួកគេរកចំណូលបានច្រើនជាងមុន ពួកគេមិនមានច្បាប់ចម្លងសំបុត្រកំណើតគ្រប់គ្រាន់ (ឧទាហរណ៍ នៅក្នុងស្រុក ស៊ីធរកណ្តាល និងស្រុកពារាំង ខេត្តព្រៃវែង) និងទទួលបានការរិះគុណពីសំណាក់ប្រជាជនពីសេវាដែលមានតម្លៃខ្ពស់ពីការធ្វើច្បាប់ចម្លងសំបុត្រកំណើត លិខិតលិខិតអាពាហ៍ពិពាហ៍ លិខិតបញ្ជាក់ភាពនូវលីវ លិខិតបញ្ជាក់ប្រវត្តិដីធ្លី និងលិខិតជួលផ្ទះ។[8] តារាងទី១ បានបង្ហាញពីតម្លៃក្នុងការផ្តល់សេវានៅថ្នាក់ឃុំនេះមានតម្លៃត្រឹម ដែលចាប់ពី ៤០០០រៀល រហូតដល់១៥.០០០រៀល។[9] ថ្វីបើតម្លៃនេះមើលទៅហាក់ដូចជាសមរម្យក្នុងឆ្នាំ២០១៤ ប្រជាជនមួយចំនួននៅតែទទួលអារម្មណ៍ថាតម្លៃនេះវានៅតែខ្ពស់។ "វាប្រហែលមកពីតាំងពីដើមមក ប្រជាពលរដ្ឋទទួលបានសេវាសាធារណៈទាំងអស់នេះដោយមិនគិតថ្លៃ ហេតុនេះវាបានធ្វើឲ្យមានប្រត្តិកម្មពីសំណាក់ប្រជាពលរដ្ឋ។[10]

**តារាងទី១៖ តម្លៃសេវាសំខាន់ៗទាំងប្រាំនៅថ្នាក់ឃុំ**

| ល.រ | បរិយាយ | កម្រៃសេវា (គិតជារៀល) | កម្រៃសេវា គិតជាដុល្លារ | ពេលវេលា ដំណើរការ |
|---|---|---|---|---|
| ១ | ច្បាប់ចម្លងសំបុត្រកំណើត | ១០០០០ | ២.៥០ | ៣ |
| ២ | លិខិតអាពាហ៍ពិពាហ៍ | ១៥០០០ | ៣.៧៥ | ៣ |
| ៣ | លិខិតបញ្ជាក់ភាពនូវលីវ | ៥០០០ | ១.២៥ | ៣ |
| ៤ | លិខិតបញ្ជាក់ប្រវត្តិដីធ្លី | ១០០០០ | ២.៥០ | ៧ |
| ៥ | លិខិតបញ្ជាក់ជួលផ្ទះ | ៥០០០ | ១.២៥ | ៧ |

Source: RGC, “Inter-Ministerial Prakas on the Provision of Administrative Service to Sub-National Administration,” Phnom Penh, 2013, p. 23-24.

[6] *Ibid*
[7] *Ibid*
[8] T. S. R. 6, *Reprt on the Results of District Forum on Commune Public Services of Sithor Kandal and Pearang Districts* (2014).
[9] *Ibid*
[10] *Ibid*

ដោយសារតែមានប្រត្តិកម្មយ៉ាងខ្លាំងពីសំណាក់ប្រជាពលរដ្ឋយ៉ាងដូច្នោះ តម្លៃសេវាសាធារណៈទាំអស់នោះត្រូវបំញុះ៥0ភាគរយ% នៅក្នុងស្រុកបារភ្នំ។[11]
បន្ថែមពីនេះទៅទៀត ប្រជាពលរដ្ឋដែលមានប័ណ្ណសំគាល់គ្រួសារក្រីក្រ កម្រិត១ កម្រិត២ កម្រិត៣ នឹងមិនត្រូវបានគិតកម្រៃពីសេវានេះទេ។[12] បន្ទាប់ពីការបញ្ចុះតម្លៃរួចមក ប្រជាពលរដ្ឋហាក់ដូចជាពេញចិត្តនឹងតម្លៃថ្មីរបស់សេវាកម្មទាំងនោះ។[13] នេះសបង្ហាញអោយឃើញថាកម្មវិធីលើកកម្ពស់ការយល់ដឹងនេះនឹងត្រូវបានអនុវត្តដើម្បីពន្យល់ និងផ្តល់ពត៌មាន បន្ថែមទៅដល់អ្នកភូមិអំពីបច្ចុប្បន្នភាពនៃកម្រៃរបស់សេវា។[14]

## ៣. ឃុំ/សង្កាត់មានសុវត្ថិភាព

ក្រុមប្រឹក្សា ឃុំ/សង្កាត់មានភារកិច្ចរក្សាសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ។[15] ដើម្បីពង្រឹងសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ ក្រសួងមហាផ្ទៃបានចាប់ផ្តើមគោលនយោបាយភូមិ-ឃុំ/សង្កាត់ មានសុវត្ថិភាពព្រមជាមួយនឹងគោលការណ៍ណែនាំនៅក្នុងឆ្នាំ២០១០[16] ដែលមានចែង លក្ខណៈសម្បត្តិ៩យ៉ាងដូចជា៖ ១)គ្មានសកម្មភាពលួច ឆក់ ប្លន់គ្រប់ប្រភេទ ២)គ្មាន ការផលិត និងការជួញដូរគ្រឿងញៀនខុសច្បាប់ ៣)គ្មានការជួញដូរស្ត្រី គ្មានការជួញដូរកុមារ និងអំពើហឹង្សាក្នុងគ្រួសារ ៤)គ្មានក្មេងទំនើង ៥)គ្មានល្បែងស៊ីសងខុសច្បាប់ គ្មានការប្រើប្រាស់អាវុធខុសច្បាប់ និងបទល្មើស គ្រប់ប្រភេទ ៦)គ្មានគ្រោះថ្នាក់ចរាចរណ៍ ៧)គ្មានគ្រោះថ្នាក់ដោយសារយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ៨)មានវិធានការទប់ស្កាត់ គ្រប់គ្រង និងឆ្លើយតបចំពោះគ្រោះមហន្តរាយប្រកបដោយប្រសិទ្ធភាព ៩)គ្មានការត្រួតពិនិត្យខុសច្បាប់។[17]

**តារាងទី២៖ លក្ខណៈសម្បត្តិសំខាន់ៗរបស់ភូមិ ឃុំ/សង្កាត់មានសុវត្ថិភាពនៅក្នុងខេត្តព្រៃវែង**

| ល.រ | បរិយាយ | ២0១២ | ២0១៣ | ២0១៤ |
|---|---|---|---|---|
| ១ | ផលធៀបចំនួនគ្រួសារមានអំពើហឹង្សាក្នុង១000គ្រួសារ | ៦.៦ | ៥.៩ | ៤.៧ |
| ២ | ផលធៀបករណីចាប់រំលោភនៅក្នុងប្រជាជន១0ម៉ឺននាក់ | ២.៧ | ៣.៩ | ៥.0 |
| ៣ | ផលធៀបករណីជួញដូរស្ត្រីនៅក្នុងប្រជាជន១0ម៉ឺននាក់ | 0.៤ | 0.៧ | 0.១ |
| ៤ | ផលធៀបគ្រួសាមានសមាជិកប្រើប្រាស់គ្រឿងញៀនក្នុង១000គ្រួសារ | 0.១ | 0.១ | 0.២ |
| ៥ | ផលធៀបករណីឃាតកម្ម ប្លន់ ចាប់ជំរឹតក្នុងប្រជាជន១0ម៉ឺននាក់ | ១.0 | ១0.២ | ៣.៤ |
| ៦ | ផលធៀបករណីលួចនៅក្នុងប្រជាជន១0ម៉ឺននាក់ | ២៥.៨ | ២0.៦ | ១៩.៣ |

[11] Communication between a commune chief of Bar Phnom District and secretariat of the Senate group 6. The discount of these services have been discussed and approved by the commune council, and endorsed by the Bar Phnom District Governor.
[12] Ibid.
[13] Ibid.
[14] Ibid.
[15] Kram, *The Law on the Administration and Management of Commune/Sangkat*.
[16] MoI, *Safety Village Commune/Sangkat Policy Guideline.* (Phnom Penh: Available online: http://sithi.org/admin/upload/law/Village%20Commune%20Safety%20Policy%20(Eng)%20-%202010.pdf [Accessed 24 February 2016].
[17] *Ibid*

| | | | | |
|---|---|---|---|---|
| ៧ | ផលធៀបករណីទំនាស់កំរិតព្រហ្មទ័ណ្ឌនៅក្នុងប្រជាជន១០ម៉ឺននាក់ | ២៦.៩ | ១៦.៩ | ១៣.៩ |
| ៨ | ផលធៀបករណីទំនាស់កំរឹតរដ្ឋប្បវេណីក្នុងប្រជាជន១០ម៉ឺននាក់ | ២០២.៤ | ១៤១.១ | ១២៣.៩ |

ប្រភព: មន្ទីរផែនការខេត្ត "ឯកសារពត៌មានស្តីពីស្ថានភាពខេត្តព្រៃវែងឆ្នាំ២០១៥"

តារាងទី២ បង្ហាញអំពីស្ថានភាពរបស់ភូមិ ឃុំ/សង្កាត់មានសុវត្ថិភាពនៅក្នុងខេត្តព្រៃវែង គិតចាប់ពីឆ្នាំ២០១២ ដល់ឆ្នាំ២០១៤។[18] ស្ថិតិនេះ បង្ហាញថាផលធៀបអំពើហឹង្សាក្នុងគ្រួសារ ការជួញដូរស្ត្រី អំពើឃាតកម្ម ករណីប្លន់ចាប់ជំរឹត លួច ទំនាស់ករណីព្រហ្មទ័ណ្ឌ និងទំនាស់ករណីរដ្ឋប្បវេណីមានការថយចុះជាលំដាប់ចាប់ពីឆ្នាំ២០១២ដល់ឆ្នាំ២០១៤។ ទោះជាយ៉ាងណា ផលធៀបករណីរំលោភនៅក្នុងប្រជាជន១០ម៉ឺននាក់មានការកើនឡើងបន្តិចបន្តួច ចាប់ពី២.៧ នៅក្នុងឆ្នាំ២០១២ ទៅដល់៥.០នៅក្នុងឆ្នាំ២០១៤ និងផលធៀបរបស់គ្រួសារមានសមាជិកប្រើប្រាស់គ្រឿងញៀនក៏មានការកើនឡើងបន្តិចបន្តួចផងដែរ ចាប់ពី០.១នៅក្នុងឆ្នាំ២០១២ ទៅដល់០.២នៅក្នុងឆ្នាំ២០១៤។[19] នេះបានបង្ហាញឲ្យឃើញថាសកម្មភាពផ្សេងៗទៀតគួរតែលើកយកមកអនុវត្តដើម្បីកាត់បន្ថយករណីទាំងពីរនេះ ទោះបីជាករណីទាំងពីរនេះមានការកើនឡើងបន្តិចបន្តួចក៏ដោយ។

បន្ថែមពីនេះទៅទៀត ស្ថានភាពទូទៅរបស់ភូមិ ឃុំ/សង្កាត់មានសុវត្ថិភាពនៅក្នុងខេត្តព្រៃវែង តារាងទី៣បានបង្ហាញយ៉ាងជាក់លាក់អំពីស្ថានភាពភូមិ ឃុំ/សង្កាត់មានសុវត្ថិភាពរបស់ស្រុកបាភ្នំ ក្នុងឆ្នាំ២០១៤។ តារាងនេះបានបង្ហាញយ៉ាងច្បាស់អំពីផលធៀបករណីការជួញដូរស្ត្រីនៅក្នុងប្រជាជន១០ម៉ឺននាក់( ០ករណី )គឺមានផលធៀបទាបបំផុត ខណៈពេលដែលផលធៀបគ្រួសារមានសមាជិកប្រើប្រាស់គ្រឿងញៀននៅក្នុង១០០០គ្រួសារជាផលធៀបទាបបំផុតលំដាប់ថ្នាក់ទី២។ ផលធៀបនៃករណីទំនាស់កំរិតរដ្ឋប្បវេណីនៅក្នុងប្រជាជន១០ម៉ឺននាក់មានផលធៀបខ្ពស់បំផុតចំនួន២០៨ករណីក្នុងប្រជាជន១០ម៉ឺននាក់ ចំណាក់ថ្នាក់បន្ទាប់គឺជាផលធៀបនៃករណីទំនាស់កំរិតព្រហ្មទ័ណ្ឌក្នុងប្រជាជន១០ម៉ឺននាក់ ដែលមានចំនួន២២.៤ករណីក្នុងប្រជាជន១០ម៉ឺននាក់ និងផលធៀបករណីលួចនៅក្នុងប្រជាជន១០ម៉ឺននាក់ជាចំណាត់ថ្នាក់ជាប់ចំណាត់ថ្នាក់ទី៣ដែលមានចំនួន១៦.០ករណី។

**តារាងទី៣៖ លក្ខណៈសម្បត្តិសំខាន់ៗរបស់ភូមិ ឃុំ/សង្កាត់មានសុវត្ថិភាពនៅក្នុងស្រុកបាភ្នំ ឆ្នាំ២០១៤**

| ល.រ | បរិយាយ | ២០១៤ |
|---|---|---|
| ១ | ផលធៀបចំនួនគ្រួសារមានអំពើហឹង្សាក្នុង១០០០គ្រួសារ | ៧.២ |
| ២ | ផលធៀបករណីចាប់រំលោភនៅក្នុងប្រជាជន១០ម៉ឺននាក់ | ៨.៥ |
| ៣ | ផលធៀបករណីជួញដូរស្ត្រីនៅក្នុងប្រជាជន១០ម៉ឺននាក់ | ០ |
| ៤ | ផលធៀបគ្រួសាមានសមាជិកប្រើប្រាស់គ្រឿងញៀនក្នុង១០០០គ្រួសារ | ០.២ |
| ៥ | ផលធៀបករណីឃាតកម្ម ប្លន់ ចាប់ជំរឹតក្នុងប្រជាជន១០ម៉ឺននាក់ | ១.១ |
| ៦ | ផលធៀបករណីលួចនៅក្នុងប្រជាជន១០ម៉ឺននាក់ | ១៦.០ |
| ៧ | ផលធៀបករណីទំនាស់កំរិតព្រហ្មទ័ណ្ឌនៅក្នុងប្រជាជន១០ម៉ឺននាក់ | ២២.៤ |

[18] P. P. Department, *Information Document on Situation of Prey Veng Province in 2015.*
[19] *Ibid*

| | | |
|---|---|---|
| ៨ | ផលធៀបករណីទំនាស់កំរិតរដ្ឋប្បវេណីក្នុងប្រជាជន១០ម៉ឺននាក់ | ២០៨.០ |

ប្រភព: មន្ទីរផែនការខេត្ត "ឯកសារពត៌មានស្តីពីស្ថានភាពខេត្តព្រៃវែងឆ្នាំ២០១៥ "

ផ្តោតទៅលើលក្ខណៈសម្បត្តិរបស់ភូមិ ឃុំ/សង្កាត់មានសុវត្ថិភាព កិច្ចខិតខំប្រឹងប្រែងគួរតែត្រូវបានធ្វើឡើងដើម្បីលើកកម្ពស់សុវត្ថិភាព ភូមិ ឃុំ/សង្កាត់ អោយបានប្រសើរជាងមុន។ ខណៈពេលដែលមានការរំពឹងទុកខ្ពស់នៃឃុំ/សង្កាត់ពាក់ព័ន្ធនឹងការគ្រប់គ្រងសកម្មភាពខុសច្បាប់ តាមរយៈគោលនយោបាយខាងលើ និងដោយមានការចូលរួម ពីសំណាក់ប្រជាពលរដ្ឋ

លទ្ធភាពក្នុងការទប់ស្កាត់ឬបង្រ្កាបករណីព្រហ្មទណ្ឌនេះគឺជាទូទៅអាស្រ័យលើ ទំនាក់ទំនង និងកិច្ចសហការយ៉ាងរឹងមាំរវាងមេឃុំ/ចៅសង្កាត់ ឬក្រុមប្រឹក្សា និងប៉ូលីស។[20] ដើម្បីបំពេញតាមលក្ខណៈសម្បត្តិសុវត្ថិភាពទាំងនោះ វាចាំបាច់ត្រូវតែមានកម្លាំងមនុស្ស និងធនធានហិរញ្ញវត្ថុគ្រប់គ្រាន់ដើម្បីឲ្យការអនុវត្តមានប្រសិទ្ធិភាព។

## ៤. ទំនាក់ទំនងរវាងថ្នាក់ឃុំ និងថ្នាក់ស្រុក ព្រមទាំង ថ្នាក់ឃុំ និងប្រជាជន ពាក់ព័ន្ធនឹងតម្លៃសេវារដ្ឋបាល និងភូមិ ឃុំ/សង្កាត់មានសុវត្ថិភាព

ការទំនាក់ទំនងមានតួនាទីយ៉ាងសំខាន់ សម្រាប់ថ្នាក់ដឹកនាំឃុំ/សង្កាត់ ក្នុងការចែករំលែក ពិគ្រោះយោបល់ និងទទួលបាននូវការអនុញ្ញាតដើម្បីអនុវត្តសកម្មភាពការងារផ្សេងៗពីថ្នាក់ស្រុក និងថ្នាក់ភូមិ។ ទំនាក់ទំនងអាចបង្កើតបានរវាងបុគ្គល ឬក្រុមឡាំងឡាយ នៅពេលដែលពួកគេមានផលប្រយោជន៍ទៅវិញទៅមកទាំងសងខាង។[21] ក្នុងន័យនេះ ប្រជាជន និងក្រុមប្រឹក្សាឃុំ គួរតែធ្វើការប្រាស្រ័យទាក់ទងគ្នាទៅវិញទៅមកសម្រាប់ផលប្រយោជន៍ទ្វេភាគី ទៅលើសេវាសាធារណៈ ខណៈដែលក្រុមប្រឹក្សាឃុំគួរតែប្រាស្រ័យទាក់ទងជាមួយក្រុមប្រឹក្សាស្រុកពាក់ព័ន្ធនឹងតួនាទី និងការទទួលខុសត្រូវរបស់ពួកគាត់។ ឃុំ/សង្កាត់ មានកិច្ចប្រជុំជាផ្លូវការចំនួនពីរដងក្នុងមួយខែ ដែលកិច្ចប្រជុំមួយធ្វើឡើងក្នុងកម្រិតភូមិ និងកិច្ចប្រជុំមួយទៀតរៀបចំឡើងក្នុងកម្រិតស្រុកដើម្បីពិភាក្សាតួនាទីរបស់ពួកគាត់ ធ្វើបទបង្ហាញអំពីរបាយការណ៍ ស្វែងរកយោបល់ សេចក្តីសម្រេច និងអនុវត្តផែនការសម្រាប់មូលដ្ឋានរបស់ពួកគាត់។ ប្រភេទនៃទំនាក់ទំនងដែលពួកគាត់ប្រើប្រាស់រួមមាន៖ ទំនាក់ទំនងផ្ទាល់ (face to face communication) ទំនាក់ទំនងតាមទូរស័ព្ទ ទំនាក់ទំនងតាមសំបុត្រ និងតាមរបាយការណ៍។ ទំនាក់ទំនងផ្ទាល់ និងតាមទូរស័ព្ទ គឺមានសារៈសំខាន់ណាស់ដើម្បីសុំការបញ្ជាក់អះអាង និងសុំការសម្រេចមិនផ្លូវការសម្រាប់ការអនុវត្តការងារ ខណៈដែលទំនាក់ទំនងតាមសំបុត្រ និងតាមរបាយការណ៍នានា គឺជាប្រភេទនៃទំនាក់ទំនងដែលមានលក្ខណៈផ្លូវការជាង។ បន្ថែមលើនេះទៀត ប្រធានឃុំ/ចៅសង្កាត់មួយចំនួនអាចប្រើប្រាស់អ៊ីម៉ែល និងបណ្តាញសង្គមហ្វេសបុកផងដែរ។

ទំនាក់ទំនងដែលមានប្រសិទ្ធិភាព តម្រូវឲ្យមានបណ្តុំនៃជំនាញ រួមមាន៖ ការស្តាប់ដែលមានលក្ខណៈចូលរួម ភាសាកាយវិការ សមត្ថភាពក្នុងយល់ និងទំនាក់ទំនងច្បាស់លាស់។ ទោះបីជាយ៉ាងណាក៏ដោយ ជាញឹកញាប់គេសង្កេតឃើញ មានការយល់ច្រឡំដែលបណ្តាលមកពីឧបសគ្គមួយចំនួន ដូចដែលបានសង្ខេបខាងក្រោម៖[22]

---

[20] S. Sovannarith, *Enhancing Local Development of Sangkat in Phnom Penh* (2016).

[21] I. V. C. Ongkiko & A. G. Flor, *Introduction to development communication* (Los Banos, Philippines SEAMEO-SEARCA and UP Open University, 2006).

[22] E. M. Saad., 'Communication ', *Organization Behavior* (2007 Prentice Hall Inc, 2007).

- *តម្រង៖* បុគ្គលម្នាក់ (ឧ៖ អ្នកផ្ញើ) នៅក្នុងការទំនាក់ទំនងមានពេលខ្លះ អាចផ្លាស់ប្តូរព័ត៌មានដើម្បីទទួលបានចំលើយវិជ្ជមានពីអ្នកទទួលព័ត៌មាន
- *ការយល់ឃើញដោយជ្រើសរើស៖* មនុស្សធ្វើការបកស្រាយ ដោយមានលក្ខណៈជ្រើសរើសទៅលើអ្វីដែលពួកគាត់មើលឃើញ ដោយផ្អែកលើមូលដ្ឋាននៃផលប្រយោជន៍របស់ពួកគាត់ ប្រវត្តិ បទពិសោធន៍ និងអត្តចរិករបស់ពួកគាត់
- *ព័ត៌មានច្រើនហួសហេតុ៖* ជាលក្ខខណ្ឌមួយដែលព័ត៌មានទទួលបាន លើសពីសមត្ថភាពដែលមនុស្សម្នាក់អាចដោះស្រាយបាន
- *អារម្មណ៍ (Emotions)៖* ខណៈពេលដែលទទួលបានសារ/ព័ត៌មានមួយ ថាតើអ្នកទទួលព័ត៌មានមានអារម្មណ៍យ៉ាងដូចម្តេច នឹងជះឥទ្ធិពលលើរបៀបនៃការបកស្រាយ សារ/ព័ត៌មាននោះ
- *ភាសា៖* ពាក្យពេចន៍ មានអត្ថន័យផ្សេងៗ ចំពោះមនុស្សផ្សេងៗគ្នា។

ទំនាក់ទំនងរវាងក្រុមប្រឹក្សាឃុំ និងប្រជាជនគួរតែបង្កើតឲ្យមាន "សហគមន៍" មួយ ដែលត្រូវបានចាត់ទុកជា វិធីសាស្ត្រសាមញ្ញមួយ ដោយ សហគមន៍នោះ ជាទីកន្លែងមួយដែលជំរុញឲ្យប្រជាជនភ្ជាប់ទំនាក់ទំនងគ្នាទៅវិញទៅមកទៅតាមរបៀប និងកម្រិតផ្សេងៗគ្នា។[23] ខណៈដែល ប្រជាជន និងក្រុមប្រឹក្សាឃុំយល់ឃើញថាពួកគាត់ជាម្ចាស់កម្មសិទ្ធិរបស់សហគមន៍មួយនោះ ការប្រាស្រ័យទាក់ទង និងការទំនាក់ទំនងគ្នា តាមរយៈការទាក់ទងផ្ទាល់ត្រូវបានបង្កើតឡើង។ ទោះបីជាយ៉ាងណាក៏ដោយ ភាពជាដៃគូ ពេលខ្លះ អាចជម្រុញឲ្យមានការយល់ឃើញដោយមានការជ្រើសរើសខ្លាំង ហើយ ការណ៍នេះជះឥទ្ធិពលទៅលើអារម្មណ៍ដែលជាកម្មសិទ្ធិរបស់សហគមន៍មួយនោះ។

ពាក់ព័ន្ធនឹងសេវាសាធារណៈ ក្រុមប្រឹក្សាឃុំ ក៏មានការទទួលខុសត្រូវតាមរយៈតួនាទីរដ្ឋបាលរបស់ពួកគាត់ដើម្បីចូលរួមអនុវត្តការងារជាមួយរដ្ឋាភិបាលថ្នាក់ជាតិក្នុងជំរុញឲ្យមានសុខមាលភាពនៅក្នុងតំបន់របស់ពួកគាត់។[24] ទោះបីជា រដ្ឋាភិបាលបាននិងកំពុងផែនការយុទ្ធសាស្ត្រសម្រាប់ដំណើរការអភិបាលកិច្ចមូលដ្ឋាននៅក្នុងប្រទេសកម្ពុជា គេសង្កេតឃើញ មានបញ្ហាមួយចំនួនពាក់ព័ន្ធនឹងការប្រាស្រ័យទាក់ទងនៅកម្រិតឃុំ/សង្កាត់៖

- កង្វះការចូលរួមរបស់ប្រជាជននៅក្នុងកិច្ចប្រជុំផ្លូវការ។ ឧទាហរណ៍ ប្រសិនបើ ឃុំ ឬភូមិ រៀបចំកិច្ចប្រជុំ ប្រជាជនទាំងអស់នៅក្នុងភូមិ មិនបានចូលរួមឡើយ ហើយ ប្រសិនបើពួកគាត់មកចូលរួមការប្រជុំពួកគាត់មិនមានជាមតិអ្វីច្រើនឡើយ។[25]

[23] V. Miller, *Understanding Digital Culture* 2011).
[24] C. Mansfield & K. MacLeod, *Promoting decentralization through partnerships* (2016). Available online: Available at: http://www.pactcambodia.org/Publications/Decentralization/Commune_Council_&_Civil_Society.pdf [Accessed.
[25] Kim Chhornm et al., *Assessment of the second term of decentralization in Cambodia: Commune Council Performance and Citizens' Participation, 2007 -2012* (2016). Available online: Available at: http://comfrel.org/eng/components/com_mypublications/files/390033Final_ report_of_the_ Second_Term_of_DD_English.pdf [Accessed.

- កង្វះនូវការប្រាស្រ័យទាក់ទងគ្នារវាងរដ្ឋ និងប្រជាជន។ ប្រជាជនមួយចំនួនធំ ហាក់ដូចជា មិនសូវមានចំណាប់អារម្មណ៍ និង មិនចង់ចោទសួរទៅលើបញ្ហាដែលពួកគាត់មានកង្វល់។[26]
- កង្វះនូវកិច្ចសន្ទនាដែលមានការបើកទូលាយ អាចកើតឡើងក្នុងកិច្ចប្រជុំក្រុមប្រឹក្សាឃុំ ព្រោះថាសម្លេងរបស់ប្រជាជនហាក់ដូចជាត្រូវបានសំពាធដោយអាជ្ញាធរ។[27]

ការកែលម្អការទំនាក់ទំនងរវាងផ្នែកខាងក្រោម និងផ្នែកខាងលើអាចបញ្ជាក់ពីភារកិច្ចរបស់ឃុំ/សង្កាត់ និងជួយកែរកាត់បន្ថយការយល់ច្រលំរវាង ក្រុមប្រឹក្សាឃុំ អភិបាលស្រុក ប្រធានភូមិ និងអ្នកភូមិដែលជាតួអង្គសំខាន់សម្រាប់ចូលរួមចំណែកក្នុងការប្រាស្រ័យទាក់ទងល្អ។ម្យ៉ាងវិញទៀត អាជ្ញាធរ មូលដ្ឋានអាច អនុញ្ញាតឱ្យមាន មតិ បន្ថែមទៀតពីសំណាក់ប្រជាពលរដ្ឋតាមរយៈ ការចូលរួមក្នុងន័យស្ថាបនាដើម្បី លើកកម្ពស់ សេវាសាធារណៈ ក្នុងតំបន់។

## ៥. សន្និដ្ឋាន

ឯកសារទស្សនាទាននេះស្វែងយល់ពីការបញ្ហាប្រឈមនៃការផ្តល់សេវារដ្ឋបាលនៅថ្នាក់ឃុំ សង្កាត់ ដោយផ្តោតលើការអនុវត្តកម្រៃសេវាកម្ម សុវត្ថិភាព ការទំនាក់ទំនងរវាងក្រុមប្រឹក្សាឃុំជាមួយថ្នាក់ស្រុក ថ្នាក់ភូមិ និងប្រជាពលរដ្ឋ។ ការសិក្សាបានរកឃើញថាបញ្ហាចំបងនៃការផ្តល់សេវារដ្ឋបាល គឺទាក់ទងទៅនឹងគុណភាពសេវាកម្មដោយខ្វះសំភារៈ និងការរវល់ការងារច្រើនរបស់ថ្នាក់ឃុំ សង្កាត់។ ហើយការយកថ្លៃសេវាកម្មក៏មានតម្លៃខ្ពស់សំរាប់គ្រួសារក្រីក្រ។ ការពន្យល់បង្ហាញ និងការផ្សព្វផ្សាយពីសារៈសំខាន់នៃការអនុវត្តសេវាកម្មអាចធ្វើឲ្យប្រជាជនយល់ពីចំនុចសំខាន់នៃការយកសេវាកម្ម។

ចំពោះការងារសុវត្ថិភាព ឃុំ សង្កាត់មានលក្ខណ៍៩ចំនុច ដើម្បីក្លាយជាភូមិ ឃុំមានសុវត្ថិភាព។ ការសិក្សាបង្ហាញថាអត្រានៃការប្រើប្រាស់គ្រឿងញាន និងអំពើចាប់រំលោភមានការកើនឡើងខ្លះពីឆ្នាំ ២០១២ ទៅ ២០១៤ សំរាប់ការរំលោភពី ២,៧ ទៅ ៥,០ ក្នុងចំណោមមនុស្ស ១០ម៉ឺនគ្រួសារ ហើយការប្រើប្រាស់គ្រឿងញានពី ០,១ ទៅ ០,២ ក្នុង១០ម៉ឺននាក់។ ដើម្បីលុបបំបាត់បញ្ហានេះ និងឆ្លើយតបទៅភូមិ ឃុំ មានសុវត្ថិភាព តម្រូវឲ្យមានធនធានមនុស្ស និងថវិកាគ្រប់គ្រាន់ក្នុងការអនុវត្តការងារ និងតម្រូវឲ្យមានភាពសហការល្អរវាង ឃុំ សង្កាត់ជាមួយនគរបាលមូលដ្ឋាន និងការចូលរួមជាមួយប្រជាជនដើម្បីឲ្យការងារមានប្រសិទ្ធិភាពខ្ពស់។

ចំពោះកិច្ចទំនាក់ទំនងរបស់ឃុំ សង្កាត់ គេសង្កេតឃើញមានកង្វះខាតមួយចំនួនរួមមាន៖ មានការខ្វះខាតការចូលរួមរបស់ប្រជាជនមូលដ្ឋានក្នុងការប្រជុំ និងពិភាក្សាទូលំទូលាយ និងការប្រកាន់បក្សពួក ហើយការងារតម្រូវឲ្យឃុំ សង្កាត់មានភាពទទួលខុសត្រូវក្នុងការបំរើប្រជាជនស្មើភាព និងតម្រូវឲ្យការបង្កើតសមត្ថភាពទំនាក់ទំនងបានល្អរវាងឃុំ សង្កាត់ និងប្រជាជនមូលដ្ឋាន។

---

[26] Mun Vong, 'Social Accountability in Service Delivery in Cambodia' (2016).
[27] W. Bank & A. Foundation, *Voice, Choice and Decision: A Study of Local Governance Processes in Cambodia* (2016). Available online: available at: http://asiafoundation.org/resources/pdfs/voicechoicedecisionlocalgovCB.pdf [Accessed.

## គន្ថនិទ្ទេស


6, T. S. R. 2014 *Reprt on the Results of District Forum on Commune Public Services of Sithor Kandal and Pearang Districts*.

Bank, W. & A. Foundation 2016 *Voice, Choice and Decision: A Study of Local Governance Processes in Cambodia*.

COMFREL 2013 *Assessment of the Second Term of Decentralization in Cambodia: Commune Council Performance and Citizens' participation 2007-2012*.Phnom Penh

Department, P. P., *Information Document on Situation of Prey Veng Province in 2015.*

EIC 2010 *Report of the Second Citizen Satisfaction Survey in Target Commune of the Laar Project*.Phnom Penh.

Kim Chhornm, B. Blang & P. Koul 2016 *Assessment of the second term of decentralization in Cambodia: Commune Council Performance and Citizens' Participation, 2007 -2012*.

Kram, R., *The Law on the Administration and Management of Commune/Sangkat.* Phnom Penh:

Mansfield, C. & K. MacLeod 2016 *Promoting decentralization through partnerships*.

Miller, V., *Understanding Digital Culture*,2011.

MoI, *Safety Village Commune/Sangkat Policy Guideline.* Phnom Penh: Available online: http://sithi.org/admin/upload/law/Village%20Commune%20Safety%20Policy%20(Eng)%20-%202010.pdf [Accessed 24 February 2016].

Mun Vong, 'Social Accountability in Service Delivery in Cambodia' (2016).

Ongkiko, I. V. C. & A. G. Flor, *Introduction to development communication*. Los Banos, Philippines SEAMEO-SEARCA and UP Open University,2006.

RGC, *Inter-ministrial praka on the provision of administrative services to sub-national administration.* Phnom Penh:

RGC, *Inter-MInistrial Prakas on the Provision of Administrative Services to Sub-National Administration* Phnom Penh:

Robinson, M., 'Introduction: Decentralising Service Delivery ? Evidence and Policy Implications'. IDS Bulletin 38 conducted by no.1 2007. Available online: ftp://ftp.solutionexchange-un.net.in/public/decn/cr/res09070813.pdf.

Saad., E. M., 'Communication ', *Organization Behavior* 2007 Prentice Hall Inc, 2007.

Sovannarith, S. 2016 *Enhancing Local Development of Sangkat in Phnom Penh*.